# គោលការណ៍

# ជាមូលដ្ឋាន

# ស្ដីពី

# តួនាទីរបស់មេធាវី

# គោលការណ៍ជាមូលដ្ឋានស្ដីពីតួនាទីរបស់មេធាវី

Basic Principles on the Role of Lawyers

ត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ ស្ដីពីការបង្ការបទល្មើស
និងការប្រព្រឹត្តលើជនល្មើសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុងឡាហាវ៉ាន ប្រទេសគុយបា ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា
ឆ្នាំ១៩៩0 ហើយត្រូវបានគាំទ្រដោយសេចក្ដីសំរេចចិត្តលេខ៤៨/១៣៧ ចុះថ្ងៃទី២0 ខែធ្នូ ឆ្នាំ១៩៩៣ របស់មហាសន្និបាត អ.ស.ប.។

*ដោយហេតុថា* នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍ នៅលើពិភពលោក អះអាងពីការប្ដេជ្ញាចិត្តរបស់ខ្លួនថា នឹងបង្កើតនូវលក្ខខណ្ឌនានាដែលអាចរក្សាបាននូវយុត្តិធម៌ និងប្រកាសថា នេះគឺជាផ្នែកមួយនៃបំណងប្រាថ្នារបស់គេ ចំពោះសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការលើកស្ទួយ និងជំរុញឱ្យមានការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដោយគ្មានការបែងចែកពូជសាសន៍ ភេទ ភាសា និងសាសនាឡើយ ។

*ដោយហេតុថា* សេចក្ដីថ្លែងការណ៍ជាសាកលស្ដីពីសិទ្ធិមនុស្ស គាំទ្រគោលការណ៍សមភាពចំពោះមុខច្បាប់ គោលការណ៍ស្ដីពីការសន្មត់ជាមុនថាគ្មានទោស សិទ្ធិទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការមួយឯករាជ្យ និងមិនលំអៀង ព្រមទាំងការធានាទាំងអស់ដែលចាំបាច់សំរាប់ការការពារដល់ជនគ្រប់រូបដែលត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប្រកាសជាបន្ថែមទៀតពីសិទ្ធិទទួលបាននូវការជំនុំជំរះដោយគ្មានការពន្យាពេលមិនសមហេតុផល និងសិទ្ធិទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ និងជាសាធារណៈ ដោយតុលាការមួយមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ហើយដែលតុលាការនេះត្រូវបានបង្កើតឡើងដោយច្បាប់ ។

*ដោយហេតុថា* កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រំលឹកពីកាតព្វកិច្ចនៃរដ្ឋជាសមាជិកក្រោមកតិកាសញ្ញានេះ អោយលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាព ។

*ដោយហេតុថា* គោលការណ៍សមូហកម្មសំរាប់ការការពារជនគ្រប់រូបដែលស្ថិតក្រោមការឃុំឃាំង ឬការដាក់ពន្ធនាគារតាមទំរង់ណាក៏ដោយចែងថា អ្នកជាប់ឃុំឃាំងត្រូវមានសិទ្ធិទទួលបានជំនួយ ព្រមទាំងធ្វើទំនាក់ទំនង និងប្រឹក្សាយោបល់ជាមួយស្មាក្តី ។

*ដោយហេតុថា* បញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស ផ្តល់អនុសាសន៍ជាពិសេសថា ជំនួយផ្នែកច្បាប់ និងទំនាក់ទំនងជាសំងាត់ជាមួយស្មាក្តី គួរត្រូវបានធានាចំពោះពិរុទ្ធជនទាំងអស់ ។

*ដោយហេតុថា* សេចក្តីថ្លែងការណ៍ស្តីពីការធានាអោយមានការការពារចំពោះជនទាំងអស់ដែលប្រឈមមុខនឹងទោសប្រហារជីវិត ធ្វើការគូសបញ្ជាក់ជាថ្មី ពីសិទ្ធិនៃជនរាល់រូបដែលសង្ស័យ ឬដែលត្រូវចោទប្រកាន់ពីបទអាជ្ញាដែលអាចកាត់ទោសប្រហារជីវិត អោយមានជំនួយផ្នែកច្បាប់គ្រប់គ្រាន់ នៅគ្រប់តំណាក់កាលទាំងអស់នៃនីតិវិធី អនុលោមតាមមាត្រា១៤ នៃកតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

*ដោយហេតុថា* សេចក្តីថ្លែងការណ៍នៃគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌សំរាប់ជនរងគ្រោះនៃបទអាជ្ញា និងការរំលោភអំណាច ផ្តល់អនុសាសន៍អោយចាត់វិធានការនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីកែលំអពីសិទ្ធិទទួលបានយុត្តិធម៌ និងការប្រព្រឹត្ត បដិទាន ការទូទាត់សំណង និងការជួយឧបត្ថម្ភដល់ជនរងគ្រោះដោយសារបទអាជ្ញាអោយបានត្រឹមត្រូវវិញ ។

*ដោយហេតុថា* ការការពារគ្រប់គ្រាន់ដល់សិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្ត ដែលជនគ្រប់រូបសុទ្ធតែមានសិទ្ធិទទួលបាន ទោះជាសិទ្ធិទាំងនោះជា សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏នៅតែតំរូវអោយជនគ្រប់រូប មានសិទ្ធិទទួលបាននូវសេវាកម្មផ្នែកច្បាប់ដ៏មានប្រសិទ្ធិភាព ដែលផ្តល់ដោយអ្នកប្រកបវិជ្ជាជីវៈច្បាប់ឯករាជ្យមួយ ។

*ដោយហេតុថា* សមាគមវិជ្ជាជីវៈមេធាវីនានាដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកំពស់បទដ្ឋានវិជ្ជាជីវៈ និងបញ្ញត្តិក្រមសីលធម៌ ក្នុងការការពារសមាជិករបស់ខ្លួន ពីការចោទប្រកាន់ និងការដាក់កំហិតមិនសមរម្យ និងការរំលោភបំពាន ក្នុងការផ្តល់សេវាកម្មច្បាប់ដល់ជនគ្រប់រូបដែលត្រូវការមេធាវី ព្រមទាំងក្នុងការសហការជាមួយស្ថាប័នរដ្ឋាភិបាល និងស្ថាប័នដទៃទៀត ដើម្បីឆ្ពោះទៅកាន់ទីបំផុតនៃយុត្តិធម៌ និងផលប្រយោជន៍សាធារណៈ ។

គោលការណ៍ជាមូលដ្ឋានស្តីពីតួនាទីរបស់មេធាវី ដូចមានចែងខាងក្រោមនេះ ដែលត្រូវបានបង្កើតឡើងដើម្បីជួយរដ្ឋជាសមាជិកនានា ក្នុងការបំពេញភារកិច្ចរបស់ខ្លួនសំរាប់ធានា និងលើកស្ទួយនូវតួនាទីដ៏ត្រឹមត្រូវរបស់

មេធាវីដែលរដ្ឋាភិបាលទាំងឡាយគួរយកមកពិចារណា និងគោរពតាមក្នុងក្របខ័ណ្ឌនៃច្បាប់ជាតិរបស់ខ្លួន និងក្នុងការអនុវត្តជាក់ស្តែង ហើយមេធាវី និងអ្នកដទៃទៀតដូចជាចៅក្រម ព្រះរាជអាជ្ញា សមាជិកនៃអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ និងសាធារណៈជនទូទៅ គួរតែយកចិត្តទុកដាក់ចំពោះគោលការណ៍ជាមូលដ្ឋាននេះ។ គោលការណ៍ទាំងនេះ ក៏ត្រូវអនុវត្តអោយបានសមរម្យផងដែរ ចំពោះជនទាំងឡាយណាដែលប្រើប្រាស់មុខងារជាមេធាវីតែមិនបានចុះបញ្ជីផ្លូវការជាមួយសមាគមមេធាវី ។

## សិទ្ធិទទួលបានមេធាវី និងសេវាកម្មច្បាប់

១- បុគ្គលគ្រប់រូបមានសិទ្ធិពឹងពាក់រកជំនួយពីមេធាវីម្នាក់តាមការជ្រើសរើសរបស់ខ្លួន ដើម្បីការពារ និងបង្កើតសិទ្ធិរបស់ខ្លួន ព្រមទាំងដើម្បីការពារខ្លួននៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើររឿងក្តីព្រហ្មទណ្ឌ។

២- រដ្ឋាភិបាលនានាត្រូវធានាថា បុគ្គលគ្រប់រូបដែលស្ថិតនៅក្រោមដែនដីរបស់ខ្លួន និងស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវទទួលបាននូវនីតិវិធីប្រកបដោយសមត្ថភាព និងយន្តការឆ្លើយតបដ៏មានប្រសិទ្ធភាព ព្រមទាំងសិទ្ធិស្មើគ្នាទទួលបានមេធាវី ដោយគ្មានការបែងចែកពីប្រភេទអ្វីទាំងអស់ ដូចជាការរើសអើងពូជសាសន៍ ពណ៌សំបុរ ដើមកំណើតជាតិពន្ធុ ភេទ ភាសា សាសនា គំនិតនយោបាយ ឬការបញ្ចេញមតិដទៃទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ ប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត។

៣- រដ្ឋាភិបាលនានា ត្រូវធានាអោយមានការផ្តល់មូលនិធិ និងប្រភពដទៃទៀតអោយបានគ្រប់គ្រាន់សំរាប់សេវាកម្មច្បាប់ដល់ជនក្រីក្រ និងតាមការចាំបាច់ ដល់ជនដទៃទៀតដែលងាយរងគ្រោះ។ សមាគមវិជ្ជាជីវៈមេធាវីនានាត្រូវសហការក្នុងការរៀបចំ និងការផ្តល់សេវាកម្ម មធ្យោបាយ និងប្រភពដទៃទៀតទាំងនេះ ។

៤- រដ្ឋាភិបាល និងសមាគមវិជ្ជាជីវៈមេធាវីនានា ត្រូវធ្វើការផ្សព្វផ្សាយពីកម្មវិធីរបស់ខ្លួន ដល់សាធារណៈជនអំពីសិទ្ធិ និងករណីយកិច្ចរបស់ពួកគេតាមផ្លូវច្បាប់ និងពីតួនាទីដ៏សំខាន់របស់មេធាវីក្នុងការការពារសេរីភាពជាសារវ័ន្តរបស់ពួកគេ។ ជនក្រីក្រ និងជនដែលងាយរងគ្រោះផ្សេងទៀត គួរត្រូវបានយកចិត្តទុកដាក់ជាពិសេសផ្តល់ជំនួយ ដើម្បីអោយពួកគេមានលទ្ធភាពអះអាងពីសិទ្ធិរបស់ពួកគេ ហើយនៅពេលដែលចាំបាច់ត្រូវរកពឹងពាក់ជំនួយពីមេធាវី ។

## ការការពារពិសេសក្នុងរឿងក្តីយុត្តិធម៌ព្រហ្មទណ្ឌ

៥- រដ្ឋាភិបាលនានាត្រូវធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងភ្លាមដល់បុគ្គលគ្រប់រូប ពីសិទ្ធិរបស់គេដែលអាចទទួលបានជំនួយពីមេធាវីម្នាក់តាមការជ្រើសរើសរបស់គេក្រោយពីការចាប់ខ្លួន ឬឃុំខ្លួន ឬនៅពេលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ។

៦- ជនណាក៏ដោយដែលមិនមានមេធាវី មានសិទ្ធិទទួលបានមេធាវីម្នាក់ដែលមានបទពិសោធន៍ និងមានសមត្ថភាពប្រហាក់ប្រហែលទៅនឹងចរិកនៃបទល្មើសដែលចោទប្រកាន់មកលើខ្លួន ក្នុងគ្រប់រឿងក្តីទាំងអស់ដែលផលប្រយោជន៍យុត្តិធម៌តំរូវយ៉ាងដូច្នេះ ដើម្បីអោយមេធាវីនោះផ្តល់នូវជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធិភាពដោយគ្មានការបង់ថ្លៃ ប្រសិនបើគេមិនមានមធ្យោបាយគ្រប់គ្រាន់ចំណាយលើសេវាកម្មបែបនេះទេ ។

៧- រដ្ឋាភិបាលនានាត្រូវធានាបន្ថែមទៀតថា ជនណាក៏ដោយដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ទោះជាត្រូវចោទ ឬមិនត្រូវចោទពីបទអាជ្ញាក៏ដោយ ត្រូវមានសិទ្ធិទទួលបានមេធាវីម្នាក់ភ្លាមក្នុងរឿងក្តីណាក៏ដោយមិនអោយលើសពីរយៈពេល ៤៨ម៉ោង ក្រោយពេលការចាប់ខ្លួន ឬការឃុំខ្លួននោះឡើយ ។

៨- អ្នកដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬអ្នកជាប់ពន្ធនាគារទាំងអស់ត្រូវតែបានផ្តល់ឱកាស ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីជួបប្រាស្រ័យទាក់ទង និងប្រឹក្សាយោបល់ជាមួយមេធាវីរបស់ខ្លួន ដោយគ្មានការពន្យាពេល ការរាំងស្ទាក់ ឬការត្រួតពិនិត្យ និងត្រូវតែជាការសំងាត់ទាំងស្រុង ។ មន្ត្រីប្រតិបត្តិច្បាប់អាចមើលឃើញ តែមិនអាចស្តាប់លឺពីការប្រឹក្សាយោបល់នេះទេ ។

## លក្ខណៈសម្បត្តិ និងការបណ្តុះបណ្តាល

៩- រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំ ត្រូវធានាថា មេធាវីត្រូវទទួលបានការអប់រំ និងបណ្តុះបណ្តាលសមស្រប ព្រមទាំងយល់ដឹងពីទស្សនៈ និងតួនាទីតាមបញ្ញត្តិក្រមសីលធម៌របស់មេធាវី និងយល់ដឹងពីសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តដែលបានទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ។

១០- រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំ ត្រូវធានាថា គ្មានការរើសអើងចំពោះបុគ្គលណាម្នាក់ដែលនឹងចូលប្រកប ឬកំពុងតែប្រកបវិជ្ជាជីវៈច្បាប់នេះដោយមូលហេតុពូជសាសន៍ ពណ៌សម្បុរ ភេទដើមកំណើទជាតិពន្ធុ សាសនា មតិនយោបាយ ឬការសំដែងមតិផ្សេងទៀត ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិប្រភពកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀតឡើយ លើកលែងតែលក្ខខណ្ឌតម្រូវឱ្យមេធាវីនោះ ត្រូវតែមានសញ្ជាតិនៃប្រទេសសាម៉ី ទើបមិនត្រូវបានចាត់ទុកថាជាការរើសអើងនោះ ។

១១- នៅប្រទេសនានាដែលមានក្រុម សហគមន៍ ឬតំបន់ ដែលសេចក្តីត្រូវការរបស់គេសំរាប់សេវាកម្មច្បាប់មិនមានដូចបំណង ជាពិសេសចំពោះក្រុមទាំងឡាយដែលមានវប្បធម៌ ភាសា ឬទំនៀមទំលាប់ផ្សេងៗគ្នា ឬក៏ធ្លាប់ជាជនរងគ្រោះនៃការរើសអើងកាលពីអតីតកាល រដ្ឋាភិបាល សមាគមវិជ្ជាជីវៈមេធាវីនានា និងស្ថាប័នអប់រំគួរតែចាត់វិធានការពិសេស ផ្តល់ឱកាសអោយបេក្ខជនដែលមកពីក្រុមទាំងនោះ បានចូលប្រកបវិជ្ជាជីវៈច្បាប់ ហើយត្រូវធានាថា ពួកគេទទួលបានការបណ្តុះបណ្តាលសមស្របទៅតាមសេចក្តីត្រូវការរបស់ក្រុមគេ។

## តួនាទី និងការទទួលខុសត្រូវ

១២- មេធាវី ត្រូវរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈរបស់ខ្លួន ជាភ្នាក់ងារដ៏សំខាន់ នៃរដ្ឋបាលយុត្តិធម៌ នៅគ្រប់ពេលវេលាទាំងអស់ ។

១៣- តួនាទីរបស់មេធាវីចំពោះកូនក្តីរបស់ខ្លួនត្រូវរួមមាន៖

ក)- ណែនាំកូនក្តីពីសិទ្ធិ និងករណីយកិច្ចស្របច្បាប់របស់គេ និងពីការងារនៃប្រព័ន្ធច្បាប់ដែលមានការពាក់ព័ន្ធដល់សិទ្ធិ និងករណីយកិច្ចស្របច្បាប់របស់គេចំពោះរឿងក្តី។

ខ)- ជួយកូនក្តី តាមរាល់មធ្យោបាយដែលសមស្រប និងចាត់ការតាមផ្លូវច្បាប់ ដើម្បីការពារផលប្រយោជន៍របស់គេ។

គ)- ជួយកូនក្តីនៅចំពោះមុខតុលាការ សាលាក្តី ឬអាជ្ញាធររដ្ឋបាលតាមការសមស្រប។

១៤- ក្នុងការការពារសិទ្ធិនៃកូនក្តីរបស់ខ្លួន និងក្នុងការលើកស្ទួយបុព្វហេតុនៃយុត្តិធម៌ មេធាវីត្រូវស្វះស្វែងលើកកំពស់សិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តដែលបានទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ហើយត្រូវធ្វើការដោយឧស្សាហ៍ព្យាយាម និងដោយសេរីនៅគ្រប់ពេលទាំងអស់ អោយស្របតាមច្បាប់ ព្រមទាំងបទដ្ឋាននិងបញ្ញត្តិក្រមសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលត្រូវបានទទួលស្គាល់ ។

១៥- មេធាវីត្រូវស្មោះត្រង់ជានិច្ចក្នុងការគោរពផលប្រយោជន៍របស់កូនក្តីខ្លួន ។

## ការធានាចំពោះដំណើរការមេធាវី

១៦- រដ្ឋាភិបាលត្រូវធានាថា ៖

ក) - មេធាវីអាចបំពេញមុខងារវិជ្ជាជីវៈទាំងអស់របស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបន្ទុចបង្អាក់ ការយាយី ឬការជ្រៀតជ្រែកដែលមិនត្រឹមត្រូវឡើយ ។

ខ) - មេធាវីអាចធ្វើដំណើរ និងប្រឹក្សាយោបល់ជាមួយកូនក្តីរបស់ខ្លួនបានដោយសេរី ទាំងនៅក្នុងប្រទេស ទាំងនៅបរទេស និង

គ) - មេធាវីមិនត្រូវទទួលរង ឬត្រូវបានគំរាមកំហែងដោយការចោទប្រកាន់តាមផ្លូវតុលាការ ឬរដ្ឋបាល ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬទណ្ឌកម្មឯទៀតចំពោះសកម្មភាពណាមួយដែលខ្លួនបានធ្វើស្របតាមបទដ្ឋាន តួនាទី និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ឡើយ ។

១៧- កាលបើមេធាវីត្រូវបានគំរាមកំហែងដល់សន្តិសុខ ដោយសារតែការបំពេញតួនាទីរបស់ខ្លួននោះ អាជ្ញាធរត្រូវតែផ្តល់ការការពារអោយបានគ្រប់គ្រាន់ដល់មេធាវីនោះ ។

១៨- មេធាវីមិនត្រូវក្លាយជាមុខសញ្ញាជាមួយកូនក្តីរបស់ខ្លួន ដោយសារតែការបំពេញតួនាទីរបស់ខ្លួនអោយកូនក្តីនោះឡើយ ។

១៩- គ្មានតុលាការ ឬអាជ្ញាធររដ្ឋបាលណាដែលបានទទួលស្គាល់សិទ្ធិមានស្មាក្តីហើយ បែរជាបដិសេធឈប់ទទួលស្គាល់នូវសិទ្ធិមានមេធាវីនៅចំពោះមុខសមត្ថកិច្ចខ្លួននោះឡើយ លុះត្រាតែមេធាវីនោះ មិនបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ជាតិ និងការអនុវត្តន៍ជាក់ស្តែង ហើយមិនស្របជាមួយនឹងគោលការណ៍នេះ ។

២០- មេធាវីត្រូវមានអភ័យឯកសិទ្ធិពីបទព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ចំពោះសារណាការពារពាក់ព័ន្ធនានាដែលធ្វើក្នុងបំណងសុចរិតក្នុងការការពារទោះជាលាយលក្ខណ៍អក្សរក្តី ជាផ្ទាល់មាត់ក្តី ឬក្នុងការបង្ហាញខ្លួនជាវិជ្ជាជីវៈរបស់ខ្លួន នៅចំពោះមុខតុលាការ សាលាក្តី ឬអាជ្ញាធរច្បាប់ ឬរដ្ឋបាលផ្សេងទៀត ។

២១-អាជ្ញាធរមានសមត្ថកិច្ចមានតួនាទីត្រូវធានាអោយមេធាវីមានសិទ្ធិទទួលបានព័ត៌មានដែលសមស្របសំណុំរឿង និងឯកសារនៅក្នុងការកាន់កាប់ ឬការគ្រប់គ្រងរបស់ខ្លួន អោយមេធាវីមានពេលវេលាគ្រប់គ្រាន់អាចផ្តល់ជំនួយផ្នែកច្បាប់ដល់កូនក្តីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ។ សិទ្ធិទទួលបាននេះ គួរតែផ្តល់អោយនៅពេលវេលាដ៏សមស្របឆាប់បំផុត ។

២២- រដ្ឋាភិបាលនានាត្រូវគោរព និងទទួលស្គាល់ថា រាល់ទំនាក់ទំនង និងរាល់ការប្រឹក្សាយោបល់រវាងមេធាវី និងកូនក្តីរបស់ខ្លួនក្នុងទំនាក់ទំនងវិជ្ជាជីវៈគឺជាការសំងាត់ ។

## សេរីភាពនៃការសំដែងមតិ និងសេរីភាពនៃការបង្កើតសមាគម

២៣- មេធាវីក៏ដូចជាប្រជាពលរដ្ឋដែរ មានសិទ្ធិទទួលបានសេរីភាពនៃការសំដែងមតិ ជំនឿ ការបង្កើតសមាគម និងការជួបប្រជុំ ។ ជាពិសេស មេធាវីត្រូវមានសិទ្ធិចូលរួមជាសាធារណៈ ក្នុងការពិភាក្សាបញ្ហាច្បាប់ រដ្ឋបាលយុត្តិធម៌ និងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ព្រមទាំងចូលរួម ឬបង្កើតជាអង្គការតាមមូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ ក៏ដូចជាចូលរួមការប្រជុំរបស់ខ្លួន ដោយមិនទទួលរងនូវការរឹតត្បិតវិជ្ជាជីវៈដោយហេតុផលនៃសកម្មភាពស្របច្បាប់ ឬសមជិកភាពរបស់ខ្លួន នៅក្នុងអង្គការស្របច្បាប់មួយ។ ក្នុងការអនុវត្តន៏សិទ្ធិទាំងនេះ ជានិច្ចកាល មេធាវីត្រូវតែធ្វើខ្លួនអោយស្របតាមច្បាប់ ព្រមទាំងបទដ្ឋាននិងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់។

## សមាគមវិជ្ជាជីវៈមេធាវី

២៤- មេធាវីត្រូវមានសិទ្ធិបង្កើត និងចូលរួមសមាគមវិជ្ជាជីវៈដែលគ្រប់គ្រងដោយខ្លួនឯង ដើម្បីតំណាងអោយផលប្រយោជន៏របស់ខ្លួន លើកស្ទួយការបណ្តុះបណ្តាល និងការអប់រំបន្ត និងដើម្បីការពារបូរណៈភាពវិជ្ជាជីវៈរបស់ខ្លួន។ អង្គភាពប្រតិបត្តិនៃសមាគមវិជ្ជាជីវៈ ត្រូវតែធ្វើការបោះឆ្នោតដោយសមាជិករបស់ខ្លួន និងត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ។

២៥- សមាគមវិជ្ជាជីវៈមេធាវីត្រូវសហការជាមួយរដ្ឋាភិបាល ដើម្បីធានាថាបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានស្មើភាពគ្នា និងប្រកបដោយប្រសិទ្ធិភាពពីសេវាកម្មច្បាប់ ហើយធានាថា មេធាវីអាចប្រឹក្សាយោបល់ និងជួយកូនក្តីរបស់ខ្លួនបាន ស្របតាមច្បាប់ និងបទដ្ឋាននិងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ ដោយគ្មានការជ្រៀតជ្រែកមិនត្រឹមត្រូវឡើយ ។

## ចំណាត់ការដាក់វិន័យ

២៦- ក្រមសីលធម៌វិជ្ជាជីវៈមេធាវីត្រូវតែបង្កើតឡើង ដោយវិជ្ជាជីវៈច្បាប់ តាមរយៈអង្គភាពដ៏សមស្របរបស់ខ្លួន ឬដោយច្បាប់ អនុលោមតាមច្បាប់ជាតិ និងប្បវេណី ប្រមទាំងបណ្តាវិធាន និងបទដ្ឋានអន្តរជាតិដែលត្រូវបានទទួលស្គាល់ ។

២៧- ការចោទប្រកាន់ ឬបណ្តឹងចំពោះមេធាវីស្ថិតក្នុងសមត្ថកិច្ចវិជ្ជាជីវៈរបស់ខ្លួន ត្រូវតែចាត់ការអោយបានឆាប់រហ័ស និងត្រឹមត្រូវតាមនីតិវិធីដែលសមស្រប។ មេធាវី ក៏ត្រូវមានសិទ្ធិទទួលបាននូវការជំនុំជំរះប្រកបដោយយុត្តិធម៌ រួមទាំងសិទ្ធិទទួលបានជំនួយពីមេធាវីម្នាក់ទៀតតាមការជ្រើសរើសរបស់គេ។

២៨- ចំណាត់ការដាក់វិន័យចំពោះមេធាវី ត្រូវតែធ្វើនៅចំពោះមុខគណៈកម្មាធិការវិន័យឥតលំអៀងមួយដែលបង្កើតឡើងដោយវិជ្ជាជីវៈច្បាប់ នៅចំពោះមុខអាជ្ញាធរឯករាជ្យមួយដែលបង្កើតដោយលក្ខន្តិកៈ ឬនៅចំពោះមុខតុលាការ និងត្រូវតែស្ថិតក្រោមការត្រួតពិនិត្យនីត្យានុកូលភាពដោយឯករាជ្យពីតុលាការ ។

២៩- រាល់ចំណាត់ការដាក់វិន័យត្រូវតែសំរេចស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋាននិងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈដទៃទៀតដែលត្រូវបានទទួលស្គាល់ ព្រមទាំងតាមស្មារតីនៃគោលការណ៍នេះ ។

~~~~~~~~~
~~~~~~~~~